ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 04 / 2012
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បតិ៍ ទី ០៥ ខែ មេសា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៥៨

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

---

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
| --- |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ដាវ អានសាន, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោកDale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT លោក Barnabé NEKUIE, លោក វ៉ែន ពៅ, លោក ហុង គីមសួន, លោកស្រី ជេត វណ្ណលី, លោកស្រី Marie GUIRAUD, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី ស៊ិន សូវន |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃព្រហស្បត្តិ៍ទី០៥ ខែមេសា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៥៥ | បញ្ចប់ម៉ោង៖ ១១.២០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣៥ | បញ្ចប់ម៉ោង៖ ១៥.00 |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ៥៥ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| **ប្រភេទបញ្ហា** | **លើកឡើងដោយ** | **ម៉ោងចាប់ផ្តើម** | **ម៉ោងបញ្ចប់** |
|---|---|---|---|
| ការជូនដំណឹងអំពីអវត្តមានលោកចៅក្រមឡាវែងជាបណ្តោះអាសន្ន | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៥ |
| ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច | មេធាវីការពារក្តី នួន ជា | ០៩.០៩ | ១៦.១០ |
| បញ្ហាទាក់ទងនឹងការតាំងសំណួរទៅសាក្សី | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ០៩.៣៥ | ០៩.៤៥ |
| ការកត់សម្គាល់នៃការដាក់បង្ហាញឯកសារ | អង្គជំនុំជម្រះ | ១០.១០ | ១០.១០ |
| ការជំទាស់ចំពោះវិសាលភាពនៃការបង្ហាញឯកសារទៅសាក្សី | សហព្រះរាជអាជ្ញា | ១០.២៥ | ១០.៤០ |

| | | | |
|---|---|---|---|
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្ដី អៀង សារី<br>មេធាវីការពារក្ដី នួន ជា | ១០.៥៥<br>១២.១០ | ១០.៥៥<br>១២.១០ |
| ការជំទាស់ចំពោះខ្លឹមសារនៃការតាំងសំណួរទៅសាក្សី | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១១.៣០ | ១១.៤០ |
| បញ្ហាទាក់ទងនឹងការបង្ហាញឯកសារ | មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ១១.៤០<br>១៣.៣៥ | ១១.៥០<br>១៣.៣៥ |
| សំណើសុំឱ្យធ្វើការបញ្ជាក់អំពីពេលវេលាសម្រាប់តាំងសំណួរទៅសាក្សី | អង្គជំនុំជម្រះ | ១៦.០៥ | ១៦.១០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការជូនដំណឹងអំពីអវត្តមានរបស់លោកចៅក្រម LAVERGNE**

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា លោកស្រីចៅក្រម Fenz និងជំនួសលោកចៅក្រម LAVERGNE ជាបណ្ដោះអាសន្នសម្រាប់សវនាការថ្ងៃនេះ ដោយសារតែគាត់មានបញ្ហាសុខភាព។

**ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច**

មេធាវីការពារក្ដី នួន ជា បានបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

**បញ្ហាទាក់ទងនឹងការតាំងសំណួរទៅសាក្សី**

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់ចំពោះការតាំងសំណួររបស់មេធាវីការពារក្ដី នួន ជា ដែលមានលក្ខណៈជាការសន្និដ្ឋាន។ អង្គជំនុំជម្រះបានបដិសេធនឹងការជំទាស់ ហើយបានរំលឹកទៅភាគីថា នៅតុលាការ អ.វ.ត.ក នេះ មិនអនុវត្តការតាំងសំណួររបៀបដូចជាតុលាការ ICTY និងICTR នោះទេ ភាគីគួរតាំងសំណួរដែលមានលក្ខណៈសាមញ្ញដែលអាចឱ្យសាក្សីងាយយល់នឹងអាច ឆ្លើយនឹងសំណួរបាន។

**ការកត់សម្គាល់នៃការដាក់បង្ហាញឯកសារ**

អង្គជំនុំជម្រះបានណែនាំថា នៅពេលដែលភាគីមានបំណងក្នុងការដាក់បង្ហាញនូវឯកសារណាមួយឱ្យសាក្សីធ្វើការបញ្ជាក់ ភាគីត្រូវស្នើដាក់បង្ហាញឯកសារនោះនៅលើអេក្រង់កុំព្យូទ័រ ព្រមទាំងផ្ដល់ឯកសារជាសន្លឹកក្រដាសទៅឱ្យសាក្សីពិនិត្យផងដែរ។

**ការជំទាស់ចំពោះវិសាលភាពនៃការបង្ហាញឯកសារទៅសាក្សី**

សហព្រះរាជអាជ្ញាបានធ្វើការជំទាស់ចំពោះមេធាវីការពារក្តី នួន ជា ក្នុងការបង្ហាញឯកសារដែលមិនមានវត្តមានរបស់សាក្សីនៅក្នុងបទសម្ភាសន៍ ទៅឱ្យសាក្សីពិនិត្យ។ អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងករណីដែលបទសម្ភាសន៍របស់បុគ្គលណាមួយ មិនមានវត្តមានរបស់សាក្សីនោះទេ មេធាវីអាចតាំងសំណួរជាលក្ខណៈទូទៅបាន ប៉ុន្តែមិនអាចដកស្រង់នៅផ្នែកណាមួយនៃបទសម្ភាសន៍មកធ្វើការតាំងសំណួរទៅសាក្សីបានឡើយ។

**ការស្នើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើ។

**ការជំទាស់ចំពោះខ្លឹមសារនៃការតាំងសំណួរទៅសាក្សី**

សហព្រះរាជអាជ្ញាបានជំទាស់ចំពោះការតាំងសំណួរទៅសាក្សីឱ្យផ្តល់មតិយោបល់ទៅលើសាលក្រមរបស់អង្គជំនុំជម្រះសំណុំរឿងលេខ០០១។ អង្គជំនុំជម្រះទទួលយកនូវការជំទាស់របស់សហព្រះរាជអាជ្ញា។

**បញ្ហាទាក់ទងនឹងការបង្ហាញឯកសារ**

មេធាវីការពារក្តី នួន ជា បានស្នើសុំដាក់បង្ហាញខ្សែវីដេអូក្នុងការតាំងសំណួរទៅសាក្សី។ សហព្រះរាជអាជ្ញាបានជំទាស់ដោយសារតែឯកសារនេះមិនមាននៅក្នុងសំណុំរឿង ហើយមេធាវីការពារក្តីមិនបានដាក់នៅក្នុងបញ្ជីឯកសាររបស់ខ្លួនដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំនេះ និងបានណែនាំឱ្យមេធាវីការពារក្តីធ្វើសំណើសុំជាលាយលក្ខណ៍អក្សរផ្អែកតាមវិធាន៨៧.៤ ប្រសិនបើគាត់ចង់បង្ហាញឯកសារនេះ។

**សំណើសុំឱ្យធ្វើការបញ្ជាក់អំពីពេលវេលាសម្រាប់តាំងសំណួរទៅសាក្សី**

អង្គជំនុំជម្រះបានស្នើសុំឱ្យមេធាវីការពារក្តីធ្វើការបញ្ជាក់អំពីពេលវេលាដែលពួកគេត្រូវការក្នុងការតាំងសំណួរទៅសាក្សី។ មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថាក្រុមខ្លួនត្រូវការរយៈពេលមួយម៉ោងដើម្បីបញ្ចប់ការតាំងសំណួរទៅសាក្សី។ មេធាវីការពារក្តី អៀង សារី បានបញ្ជាក់ថាក្រុមខ្លួនត្រូវការរយៈពេលមួយថ្ងៃ និងមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថាត្រូវការរយៈពេលមួយថ្ងៃ។ អង្គជំនុំជម្រះបានជូនដំណឹងថាសម្រាប់សវនាការថ្ងៃចន្ទ និងថ្ងៃអង្គារ៍ អង្គជំនុំជម្រះនឹងប្រគល់ឱ្យមេធាវីការពារក្តី

អៀង សារី និង ខៀវ សំផន ធ្វើការតាំងសំណួរទៅសាក្សី។

## កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣)

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/175 | D43/IV-Annex 11 | 00173883-00173894 00223903-00223903, 00583931-00583931 00280047-00280047 | [លិខិតបញ្ជាក់ការជំនូសឯកសារ] ឧបសម្ព័ន្ធ១១: 117bbkkh សម្រង់ចម្លើយសារភាពរបស់ សាន់ អ៊ាប ហៅ ខុន<br>[Surrogate Sheet] Annex 11: 117bbkkh Colour copy Excerpt of Confession of San Eap alias Khon<br>[Feuille remplacée] Annex 11: 117bbkkh l'extrait en copie couleur de la confession de San Eap alias Khon | P | 00173883 | 00583931 | 00280047 |
| E3/355 | D117 | 00239830-00239840 00242872-00242882 00239820-00239829 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ថ្ងៃទី ១៩ វិច្ឆិកា ២០០៨<br>Written Record of Interview of Duch by CIJ on 19-11-2008<br>Procès verbal d'interrogatoire de Duch par CJI le 19-11-2008 | P | 00239834 | 00242876 | 00239824 |
| E3/359 | D121/6.2 | 00408216-00408238 00434334-00434349 00408239-00408249 | សេចក្តីអត្ថាធិប្បាយនិងចម្លើយជាលាយលក្ខណ៍អក្សររបស់ឌុច ចំពោះសំនួរសរសេរ<br>Duch's written comments and answers to written questions<br>Commentaires écrits de Duch et ses réponses aux questions écrites | P | 00408238 | 00434349 | 00408249 |
| E3/61 | D87 | 00195562-00195570 00195571-00195579 00195580-00195589 | [លិខិតបញ្ជាក់ការជំនូសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០២ មិថុនា ២០០៨<br>[Surrogate Sheet] Written Record of Interview of Duch by CIJ on 02-06-2008<br>[Feuille remplacée] Procès verbal d'interrogatoire de Duch par CJI le 02-06-2008 | P | 00195564 | 00195573 | 00195582 |
| E3/1565 | 5.42 | 00017305-00017351 00182773-00182779 | ចម្លើយសារភាពរបស់ គង់ គៀន ហៅ អ៊ឹង វ៉េត នៅមន្ទីរ ស-21<br>S-21 Confession of KUNG Kien alias Eung Vet | P | | | |

00803354



| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1566 | D288/6.52/4.41 | 00320807-00320810 00327352-00327354 00327355-00327358 | ឧបសម្ព័ន្ធ ៤១៖ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០២ Annex 41: Written Record of Interview - 5 June 2002 Annexe 41: Procès-verbal d'interrogatoire 5 juin 2002 | P | 00320808-09 | 00327353 | |
| E3/1567 | 20.20 | 00172208-00172212 00002621-00002623 00384724-00384727 | អ៊ីម៉ែល របស់ចាន់ដា នាយ៉ា ផ្ញើរទៅអោយ យុ ឆាង អំពីadditional material ជាភាសាអង់គ្លេស នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០១ International MediaReport entitled "'I am in danger" by Nate THAYER International MediaReport entitled "'I am in danger" by Nate THAYER | P | 00172210 | 00002622 | 00384725 |
| E3/347 | 20.19 | 00160879-00160884, 00160889-00160920, 00002494-00002557 00160885-00160888, 00002494-00002557, 00184996-00185058 00160889-00160920, 00160921-00160974 | បទសម្ភាសន៍តាមខ្សែអាត់ជាមួយ ឌុច អតីតប្រធានសន្តិសុខខ្មែរក្រហម ស-២១ សម្ភាសន៍ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា សរសេរជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៩៩ UNHCHR Suspect Statement of KANG Keck Iev alias DUCH UNHCHR Suspect Statement of KANG Keck Iev alias DUCH | P | 00160879 | 00185055 | |
| E3/1568 | D313/1.2.406.1 | 00713919-00713993 00651862-00651907 00743328-00743384 | អត្ថបទដែលបានវាយសារឡើងវិញពីអត្ថបទសរសេរដោយដៃនៃបទសម្ភាសន៍ជាមួយ ជា ស៊ីម ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៩១ និង ហេង សំរិន ២ ខែធ្នូ ឆ្នាំ ១៩៩១ នៅទីក្រុងភ្នំពេញ RETYPED from a Handwritten interview of CHEA Sim, Phnom Penh, 3 Dec 1991, and Heng Samrin, Phnom Penh, 2 Dec 1991 Transcription dactylographique de notes manuscrites prises durant des entretiens menés avec Heng Samrin et Chea Sim à Phnom, les 2 et 3 décembre 1991 respectivement | P | 00713945-54 | 00651878-83 | 00743349-54 |
| E3/451 | D86/27 | 00187649-00187670 00204338-00204356 00186168-00186191 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០៥ ០៥ ២០០៨ Written Record of Interview of Duch by CIJ on 05-05-2008 Procès verbal d'interrogatoire de Duch par CJI le 05-05-2008 | P | 00187653 | 00204342 | 00186172 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/456 | D90 | 00198870-00198878 00198879-00198886 00198887-00198894 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៥ មិថុនា ២០០៨<br>Written Record of Interview of Duch by CIJ on 25-06-2008<br>Procès verbal d'interrogatoire de Duch par CJI le 25-06-2008 | P | 00198873 | 00198882 | 00198890 |
| E3/1569 | D86/25 | 00185465-00185472 00185473-00185479 00185480-00185487 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៩ ០៤ ២០០៨<br>Written Record of Interview of Duch by CIJ on 29-04-2008<br>Procès verbal d'interrogatoire de Duch par CJI le 29-04-2008 | P | 00185466 | 00185474 | 00185481 |
| E3/1564 | D238 | 00403873-00403883 00403884-00403893 00403894-00403903 | កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី 10-11-2009<br>Writen Record of Interview of Duch by CIJ dated 10-11-2009<br>Procès verbal d'interrogatoire de Duch par CJI le 10-11-2009 | P | 00403877 | 00403888 | 00403897 |
| E3/394 | D228 | 00398220-00398227 00398228-00398235 00398236-00398243 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះ ថ្ងៃទី ២២-១០-២០០៩<br>Written Record of Interview of Duch by CIJ on 22-10-2009<br>Procès verbal d'interrogatoire de Duch par CJI le 22-10-2009 | P | 00398224-225 | 00398231-233 | 00398239 |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | 00003141 | 00182813-14 | 00224346 |
| E3/182 | 13.2 | 00019108-00019126 00183393-00183408 00292868-00292886 | ការប្រជុំអចិន្ត្រៃយ៍ថ្ងៃទី ៩ តុលា ៧៥<br>Permanent 's meeting of committee on 9 October 1975<br>La réunion du Comité Permanent du 9 octobre 1975 | P | 00009108 | 00183393 | 00292868 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៥៥) និង នួន ជា (ម៉ោង ១២.១០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ ទាំងពីរមានភ្ជាប់មកជាមួយនិងកំណត់ហេតុនេះ) ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងនាំគាត់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ ចន្ទ ទី ០៩ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលធុន្ឌ** Roger PHILLIPS